ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ...៣៤១៣........ស.ន.ប

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញនៅពេលមានគ្រោះមហន្តរាយ

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការ ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញសេចក្តីសម្រេចលេខ ១១៥ សសរ ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពី ការបង្កើតក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ ១ .-**

ត្រូវបានបង្កើតក្រុមការងារសម្របសម្រួលការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញរបស់ក្រសួងសុខាភិបាល នៅពេលមានគ្រោះមហន្តរាយ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | តែ គុយស៊ាង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២-លោកស្រីវេជ្ជបណ្ឌិត | ប្រាក់ ពិសិដ្ឋរង្សី | ប្រធាននាយកដ្ឋានការពារសុខភាព | អនុប្រធាន |
| ៣-លោកវេជ្ជបណ្ឌិត | សុខ ស្រ៊ុន | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | អនុប្រធាន |
| ៤-លោកស្រីវេជ្ជបណ្ឌិត | តេង ស្រី | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ៥- លោកវេជ្ជបណ្ឌិត | នាង ភារិទ្ធ | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ៦- លោកវេជ្ជបណ្ឌិត | អៀន សុខគី | ប្រធានការិ.គ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន | លេខា ។ |

**ប្រការ ២ .-**

ក្រុមការងារនេះមានភារកិច្ចដូចតទៅ ៖

- សម្របសម្រួល និងសហការការងារជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងដៃគូពាក់ព័ន្ធ រៀបចំ និងដាក់ចេញនូវវិធានការត្រៀមរៀបចំ ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ នៅពេលមានគ្រោះមហន្តរាយ ។
- កៀរគរគ្រឿងបរិក្ខារ មូលដ្ឋានសម្ភារៈ មធ្យោបាយ ធនធានមនុស្ស និងហិរញ្ញវត្ថុ និងទទួលយកមូលនិធិជាវិភាគទានស្ម័គ្រចិត្ត ឬអំណោយស្ម័គ្រចិត្តពីអង្គការជាតិ-អន្តរជាតិ និងសប្បុរសជនក្នុងប្រទេស និងក្រៅប្រទេសសម្រាប់ការឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ នៅពេលមានគ្រោះមហន្តរាយ ។
- ផ្សព្វផ្សាយសភាពការណ៍គ្រោះមហន្តរាយ និងទទួលយកព័ត៌មានពីខ្សែបណ្តាយ មន្ទីរសុខាភិបាល រាជធានី ខេត្តដើម្បីចងក្រងជាវិធានការឆ្លើយតបគ្រោះមហន្តរាយ ។
- ធ្វើការប្រជុំវាយតម្លៃ និងប៉ាន់ប្រមាណរៀងរាល់ឆ្នាំការប៉ះពាល់ ខូចខាត និងបាត់បង់ និងតាមដានត្រួតពិនិត្យការឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាល ។
- ធ្វើការប្រជុំប្រចាំខែ ឬក្នុងករណីចាំបាច់ តាមការអញ្ជើញរបស់ប្រធាន ដើម្បីដកស្រង់បទពិសោធន៍ទៅតាមស្ថានភាពជាក់ស្តែង ។

**ប្រការ ៣ .-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការក្រសួងសុខាភិបាល ប្រធានអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដែលមាននាមក្នុងប្រការ ១ ត្រូវទទួលភារៈអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ,ថ្ងៃទី ០១ ខែ ៥/០៣ ឆ្នាំ២០១៤

<u>កន្លែងទទួល:</u>

- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ៧

ម៉ម_ប៊ុនហេង